**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជានៅព្រះសហគមន៍គិរីវង់ ខេត្តតាកែវ**
**ថ្ងៃទី០៣ កញ្ញា ២០១៧**

អត្ថបទទី១៖យរ ២០,៧-៩
អត្ថបទទី២៖រម ១២,១-២
ដំណឹងល្អ៖មថ ១៦,២១-២៧

បងប្អូនជាទីស្រឡាញ់!

ការប្រកាសជំនឿរបស់លោកសិលា "**លោកជាព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ**" ព្រះយេស៊ូជាព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ។ យើងមានកូនក្មេង យើងមានយុវជនថ្មីៗ យើងមានគ្រីស្តបរិស័ទខ្លះៗ យើងមានប្តីប្រពន្ធថ្មីចាស់ យើងមានបងស្រី យើងមានលោកតា យើងទាំងអស់យើងមកទីនេះដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ នៅថ្ងៃនេះ នៅក្នុងអត្ថបទយើងបានស្តាប់ "ព្រះយេស៊ូ គឺជាព្រះដែលមានព្រះជន្មគង់នៅ" ព្រះយេស៊ូជាព្រះដែលមានជីវិត និងណែនាំឲ្យយើងមានជីវិត។ សំខាន់បំផុតព្រះយេស៊ូជាជីវិត ហើយយើងធ្លាប់ស្តាប់ព្រះបន្ទូលមួយ ដែលព្រះយេស៊ូធ្លាប់មានបន្ទូលថា "**ខ្ញុំជាផ្លូវ ខ្ញុំជាជីវិត ខ្ញុំជាសេចក្តីពិត**" នៅពេលយើងចូលនៅក្នុងវិហារ យើងត្រូវការនឹកឃើញនេះ៖

ទីមួយ ព្រះយេស៊ូជា"**ផ្លូវ**" ដែលយើងដើរតាម។ បើយើងចង់ដើរតាមព្រះអង្គ យើងត្រូវតែត្រូវតែលះបង់ខ្លួនឯងចោល ត្រូវតែលីឈើឆ្កាងរបស់ខ្លួន។ ដើរតាមព្រះយេស៊ូ ជាផ្លូវមួយយ៉ាងពិសេសដែលព្រះយេស៊ូបង្ហាញឲ្យយើង ដើម្បីយើងធ្វើដំណើរនៅក្នុងជីវិតរបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃ។

ទីពីរ ព្រះយេស៊ូជា "**ជីវិត**" ណែនាំឲ្យយើងលះបង់ចោលជីវិត មានន័យថា យើងត្រូវតែគិតព្រះយេស៊ូថា "**សូមស្រឡាញ់គ្នា លើកលែងទោសឲ្យគ្នាទៅវិញទៅមក សូមស្រឡាញ់សត្រូវ សូមធ្វើជាពន្លឺ សូមធ្វើជាអំបិល សូមធ្វើជាមិត្តសម្លាញ់របស់មនុស្សដែលមិនស្រឡាញ់យើង**" ហើយនេះទាំងអស់ នេះជាព្រះបន្ទូលដែលណែនាំឲ្យយើងលះបង់ចោលនៅក្នុងជីវិតរបស់យើង ដើម្បីដើរតាមព្រះបន្ទូលនេះ។ ព្រះយេស៊ូថា យើងត្រូវលះបង់ចោល និងលីឈើឆ្កាង ដោយសារនៅក្នុងជីវិតរបស់យើង យើងមានទុក្ខលំបាក។ បងប្អូនមានបទពិសោធន៍ច្រើន នៅក្នុងទុក្ខលំបាក នៅក្នុងការអធិដ្ឋាន បញ្ហានៅក្នុងការសិក្សា បញ្ហានៅក្នុងជីវិតប្រចាំ ដើម្បីរកលុយម្ហូបអាហារ រកលុយពិនិត្យសុខភាព រកលុយដើម្បីទៅសាលា បញ្ហា

យើងមានច្រើន ទុក្ខលំបាកយើងមានច្រើន នេះជាឈើឆ្កាងដែលព្រះយេស៊ូចង់ឲ្យយើងមាន។ ក៏ប៉ុន្តែ ព្រះយេស៊ូមិនលះបង់ចោល ប្រសិនបើយើងសម្រេចចិត្តដើរតាមព្រះយេស៊ូ ទោះបីយើងមានទុក្ខលំបាក ទោះបីយើងមានបញ្ហា ទោះបីយើងមានការឈឺចាប់នៅក្នុងជីវិតយើង ឈើឆ្កាងដែលយើងលីមានព្រះយេស៊ូគង់នៅជាមួយយើង ដើម្បីលីឈើឆ្កាងដែរ ដោយសារព្រះយេស៊ូជាព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅជានិច្ច អត់ដែលចោលយើងទេ និងព្រះយេស៊ូណែនាំឲ្យយើងយកជីវិតជាអទិភាព។ ប្រសិនបើយើងគិតអំពីជីវិតរបស់យើងផ្ទាល់ យើងចូលចិត្តមានទ្រព្យសម្បត្តិ យើងចូលចិត្តមានឧបករណ៍ទំនើបៗ យើងចូលចិត្តមានអ្វីៗដែលដូចគេ ប៉ុន្តែព្រះយេស៊ូថ្ងៃនេះនិយាយថា **"ប្រសិនបើមនុស្សម្នាក់បានពិភពលោកទាំងមូលមកធ្វើជាសម្បត្តិរបស់ខ្លួន តែបាត់បង់ជីវិតនោះនឹងមានប្រយោជន៍អ្វី?"** សំខាន់បំផុតគឺជីវិត។ ទោះបីយើងមានទ្រព្យសម្បត្តិច្រើន យើងមានលុយបរិបូរណ៍ យើងមានអ្វីៗទាំងអស់គ្រប់គ្រាន់ ប៉ុន្តែពេលយើងធ្លាក់ខ្លួនឈឺជាទំងន់ យើងដូចគេដូចឯង ទោះបីយើងជាអ្នកមានក៏ដោយ ជាអ្នកក្រក៏ដោយ យើងដូចគេដូចឯង និងស្លាប់ដូចគេដូចឯង។ ដូច្នេះ ជីវិតរបស់យើង ប្រសិនបើយើងគិតតែពីផលប្រយោជន៍តាមលោកិយ ថាមានទ្រព្យសម្បត្តិច្រើន នៅពេលចុងក្រោយអត់សល់អីសោះដូចគេដូចឯង។ ជីវិតរបស់យើងមានតម្លៃនៅពេលយើងចែកសេចក្ដីស្រឡាញ់ឲ្យអ្នកដទៃ ជីវិតរបស់យើងមានតម្លៃ នៅពេលយើងយកចិត្តទុកដាក់ធ្វើតាមព្រះយេស៊ូ ដោយសារព្រះយេស៊ូមានព្រះបន្ទូលយ៉ាងច្បាស់ **"សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"**។ សម្រាប់បងប្អូនគ្រីស្តបរិស័ទ យើងត្រូវការគិត យើងធ្វើយ៉ាងម៉េច ដើម្បីធ្វើតាមព្រះយេស៊ូនៅក្នុងជីវិតរបស់យើង? ធ្វើតាមព្រះយេស៊ូមានន័យថា ចែករំលែកទាំងសេចក្ដីស្រឡាញ់ ទាំងអំណរសប្បាយ ទាំងជីវិតដែលយើងបានទទួល។ មិនមែនរស់នៅសម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែរស់នៅដើម្បីឲ្យបងប្អូនឯទៀតៗរកឃើញពន្លឺមួយនៅកន្លែងយើង។

យើងដឹងថា ប្រសិនបើយើងធ្វើតាមព្រះយេស៊ូ យើងទទួលរង្វាន់ពិសេសនៅក្នុងស្ថានបរមសុខនៅក្នុងជីវិតរបស់យើង។ ប្រសិនបើយើងធ្វើអំពើល្អ យើងនឹងទទួលរង្វាន់ដ៏ល្អ ប្រសិនបើយើងធ្វើអំពើអាក្រក់ យើងនឹងទទួលរង្វាន់យ៉ាងលំបាកដែរ ដូចព្រះយេស៊ូមានព្រះបន្ទូលថា យើងទទួលតាមអំពើដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះ សូមគិតគ្រប់ពេលវេលាអ្វីដែលខ្ញុំធ្វើ នឹងណែនាំឲ្យអ្នកដទៃមានអំណរសប្បាយ អ្វីដែលខ្ញុំធ្វើណែនាំឲ្យបងប្អូនឯទៀ

តៗមានសេចក្ដីសុខ។ ទោះបីយើងជាកុមារ យើងជាយុវជន យើងជាមនុស្សចាស់ក៏ដោយ ពីមួយថ្ងៃទៅមួយថ្ងៃ យើងបាន ជួយគេ ស្រឡាញ់គេ ស្អប់គេ មើលងាយគេ ឲ្យយើងគិតដោយសារយើងទទួលតាមអំពើដែលយើងបានប្រព្រឹត្ត។

ថ្ងៃនេះយើងអធិដ្ឋាន ដើម្បីឲ្យយើងទាំងអស់គ្នាបន្តរស់នៅ ដោយទទួលស្គាល់ថាព្រះយេស៊ូជា "**ជីវិត ជាផ្លូវ ជាសេចក្ដីពិត**"។ ព្រះយេស៊ូជាផ្លូវមួយ ដើម្បីណែនាំឲ្យយើងមានជីវិត និងដើម្បីឲ្យយើងរកឃើញសេចក្ដីពិតនៅក្នុងជីវិតយើង។

សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍យើងទាំងអស់ ដើម្បីប្រកបដោយព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ អាម៉ែន៕